# បាឋកថា

# ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងឱកាសខួប២០ឆ្នាំ នៃការចូលជាសមាជិកអាស៊ានរបស់ កម្ពុជា លើប្រធានបទ “កម្ពុជានៅក្នុងដំណើរការនៃការកសាងសហគមន៍អាស៊ាន”

**រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី ០៣ ខែឧសភា ឆ្នាំ ២០១៩**

*- ឯកឧត្តម ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា*

*-ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម*

*-ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី*

*- លោកសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្ស និស្សិត*

*ទាំងអស់ជាទីរាប់អាន*

**១-** ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ និងមានកិត្តិយសក្រៃលែង ដែលបានចូលរួមក្នុងពិធីរំលឹកខួប២០ឆ្នាំ នៃការចូលជាសមាជិក នៃ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍របស់កម្ពុជា ដែលហៅកាត់ថាអាស៊ាន។

២- ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងពាណិជ្ជកម្ម ដែលបានសហការរៀបចំកម្មវិធីដ៏មានសារៈសំខាន់នេះជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ខ្ញុំមានសេចក្តីរីករាយចំពោះវត្តមាន មន្ត្រីក្រសួងពាក់ព័ន្ធ និងសាស្ត្រាចារ្យ សិស្ស-និស្សិតមកពីបណ្តាសាកលវិទ្យាល័យចូលរួមស្តាប់បទបាឋកថានាព្រឹកនេះ។

៣- កាលពីថ្ងៃទី៣០ខែមេសា កន្លងមកនេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** បានផ្ញើសារមួយជូនចំពោះជនរួមជាតិទាំងអស់ រំលឹកអំពីប្រវត្តិនៃការចូលរួមរបស់កម្ពុជាក្នុងអង្គការតំបន់ដ៏សំខាន់ និងគូសបញ្ជាក់ពីអត្ថន័យ ក៏ដូចជាអត្ថប្រយោជន៍នានា ដែលកម្ពុជាទទួលបានក្នុងវិស័យនយោបាយ សន្តិសុខ សេដ្ឋកិច្ច សង្គម-វប្បធម៌ពីសមាជិកភាពនេះ។

៤- ការជួបជុំគ្នាព្រឹកនេះ នឹងផ្តល់ឱកាសឲ្យខ្ញុំបានចូលជ្រៅថែមទៀតក្នុងការស្វែងយល់អំពីមូលហេតុ ដែលនាំឲ្យកម្ពុជាចូលជាសមាជិកអាស៊ានតួនាទី វិភាគទាន និងផលប្រយោជន៍ទាំងឡាយ ដែលបានមកពីការចូលរួមនេះ បញ្ហាប្រឈមនានាដែលយើងជួបប្រទះ ព្រមទាំងទស្សនវិស័យនានាសម្រាប់កម្ពុជា ក្លាយជាសមាជិកសកម្ម ស្មើមុខ ស្មើមាត់ នៃសហគមន៍មួយដែលយកប្រជាជនជាស្នូល និងដែលបំរើផលប្រយោជន៍ប្រជាជនជាធំ។

***-ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី***

***- លោកសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្ស និស្សិត ទាំងអស់ជាទីរាប់អាន***

៥- **សមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍** ហៅតាមភាសាអង់គ្លេស "Association of Southeast Asian Nations - ASEAN" ត្រូវបានបង្កើត

ឡើងនៅថ្ងៃទី៨ ខែ**សីហា** ឆ្នាំ**១៩៦៧** នៅទីក្រុង**បាងកក** ប្រទេស**ថៃ** តាមរយៈ "ASEAN Declaration **គឺសេចក្តីថ្លែងការណ៍អាស៊ាន**" ឬជាទូទៅត្រូវបានហៅថា"**សេចក្តីថ្លែងការណ៍ទីក្រុងបាងកក-Bangkok Declaration**" ដែលបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីការបរទេសនៃប្រទេសសមាជិកចំនួន **៥គឺ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី** និងថៃ **ដែលជាស្ថាបនិកដំបូង**។ តាមរយៈសេចក្តីថ្លែងការណ៍នេះ អាស៊ានមានគោលដៅរួមសំខាន់៣ គឺ៖

ទី១. ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច វឌ្ឍនភាពសង្គម រក្សាសន្តិភាព និងស្ថិរភាពតំបន់

ទី២. ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជួយគ្នាទៅវិញទៅមកដើម្បីផលប្រយោជន៍រួមនៃប្រទេសជាសមាជិក និង

ទី៣. ជាវេទិកាសម្រាប់ដោះស្រាយការខ្វែងគំនិតគ្នាក្នុងតំបន់។ ទស្សវត្សឆ្នាំ ១៩៦០ គឺជាទស្សវត្ស ដែលពោពេញដោយជំលោះក្នុងតំបន់អាស៊ីអាគ្នេយ៍៖ ពេលនោះ សង្គ្រាមវៀតណាមកំពុងផ្ទុះឡើងយ៉ាងពេញទំហឹង អាមេរិកចាប់ផ្តើមទំលាក់គ្រាប់បែកនៅភាគខាងកើតកម្ពុជាតាមបណ្តោយព្រំដែនជាមួយវៀតណាម (ផ្លូវលំហូជីមិញ) ម៉ាឡេស៊ី និងហ្វីលីពីនកំពុងមានជំលោះតានតឹងជាមួយគ្នា ម៉ាឡេស៊ី និងឥណ្ឌូនេស៊ី ក៏ឈ្លោះគ្នា។

៦- នៅឆ្នាំ១៩៧៦ គឺ៩ឆ្នាំក្រោយមកទើបកិច្ចប្រជុំកំពូលអាស៊ានលើកទី ១ ត្រូវបានរៀបចំឡើងនៅឆ្នាំ១៩៧៦ នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី ដែលនៅពេលនោះប្រមុខរដ្ឋ/រដ្ឋាភិបាល នៃប្រទេសស្ថាបនិកទាំង៥ បានចុះហត្ថលេខាលើឯកសារគោលសំខាន់២របស់អាស៊ាននោះគឺ៖

**១. សេចក្តីថ្លែងការណ៍ស្តីពីកិច្ចស្រុះស្រួលអាស៊ាន (ឬហៅថា - Bali Concord I)** ដែលបានកំណត់នូវគោលដៅ និងគោលការណ៍សម្រាប់

កិច្ចសហប្រតិបត្តិការអាស៊ាន ក្នុង វិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ និង

**២. សន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍** (Treaty of Amity and Cooperation-TAC) ដែលបានកំណត់នូវគោលការណ៍គ្រឹះ និងក្រមប្រតិបត្តិសម្រាប់ទំនាក់ទំនងរវាងរដ្ឋនិងរដ្ឋ ក្នុងចំណោមប្រទេសសមាជិក និងរដ្ឋជាភាគីខាងក្រៅ ដោយប្តេជ្ញាជាមួយគ្នា មិនប្រើប្រាស់ កំលាំងក្នុងការដោះស្រាយជំលោះក្នុងចំណោមប្រទេសហត្ថលេខីទាំងអស់។

៧- ជាង៣០ឆ្នាំក្រោយមកទើបអាស៊ានមានធម្មនុញ្ញរបស់ខ្លួន។ ឯកសារគតិយុត្តដ៏កំពូលនេះ ត្រូវបានចុះហត្ថលេខាដោយប្រមុខរដ្ឋ/រដ្ឋាភិបាលអាស៊ាន នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី១៣ នៅប្រទេសសិង្ហបុរី កាលថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧ និងចូលជាធរមាននៅថ្ងៃ ទី១៥ ខែធ្នូ ឆ្នាំ២០០៨។ ឯកសារច្បាប់គោលនេះ ធ្វើអោយអាស៊ាន ដែលពីមុនជាសមាគមនៃប្រជាជាតិមួយ ប្រែក្លាយទៅជាសហគមន៍មួយមាននិតិបុគ្គលភាពលើឆាកអន្តរជាតិ សម្រាប់ធ្វើទំនាក់ទំនងជាមួយអង្គការតំបន់និងអន្តរជាតិនានា។

៨- ដើម្បីជាមូលដ្ឋានទិសដៅអនាគត អាស៊ានបានដាក់ចេញនូវទស្សនៈវិស័យរបស់ខ្លួន តាមរយៈការអនុម័តនូវឯកសារសេចក្តីថ្លែងការណ៍ទស្សនៈវិស័យអាស៊ានឆ្នាំ២០២០ (ASEAN Vision 2020)។ សេចក្តីថ្លែងការណ៍នេះ បានឆ្លុះបញ្ចាំងឲ្យឃើញយ៉ាងច្បាស់អំពីឆន្ទៈរបស់ប្រទេសសមាជិកអាស៊ាន ក្នុងការខិតខំរួមគ្នាឈានទៅសម្រេចបាននូវសហគមន៍មួយដែលមានមូលដ្ឋានគតិយុត្ត ជាអង្គការតំបន់ដើម្បីប្រជាជន និងយកប្រជាជនជាស្នូល ជាតំបន់ដែលមានសន្តិភាព សេរីភាព និងអព្យាក្រឹត្យ ។ ការដាក់ចេញ

នូវទស្សនៈវិស័យខាងលើនេះ ត្រូវបានបំពេញបន្ថែមដោយការអនុម័ត Declaration on ASEAN Concord II ដែលត្រូវបានគេស្គាល់ជាទូទៅថា Bali Concord II ដែលបានគូសបញ្ជាក់បន្ថែមទៀតថា សហគមន៍អាស៊ានឆ្នាំ ២០២០ រួមមានសហគមន៍ចំនួន៣ គឺសហគមន៍សន្តិសុខអាស៊ាន សហគមន៍សេដ្ឋកិច្ចអាស៊ាន និងសហគមន៍សង្គម-វប្បធម៌អាស៊ាន។

*ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្ស និស្សិត ទាំងអស់ជាទីរាប់អាន*

៩- **កម្ពុជា**បានសម្រេចចូលជាសមាជិកអាស៊ាន ដោយមូលហេតុ**ធំៗបួនយ៉ាងគឺ៖**

១. **គោលការណ៍មិនជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងផងគ្នា។** គោលការណ៍នេះ បានផ្តល់មូលដ្ឋានគតិយុត្តដ៏សំខាន់ដល់កម្ពុជាក៏ដូចជាដល់សមាជិកដ៏ទៃទៀតទាំងអស់ ដើម្បីការពារនូវផលប្រយោជន៍ជាតិ គេចផុតពីការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង។

២. អាស៊ានធ្វើការសម្រេចលើកិច្ចការនានាផ្អែកតាម**កុងសង់ស៊ីស** (Consensus) ការបញ្ចេញទស្សនៈ និងផ្លាស់ប្តូរយោបល់ផ្អែកនយោបាយដោយស្មើភាព និងស្មើសិទ្ធ។

៣. កម្ពុជាទទួលបាន**ផលប្រយោជន៍យ៉ាងធំធេងខាងផ្នែកសេដ្ឋកិច្ច** តាមរយៈការអភិវឌ្ឍន៍សង្គម ការពង្រីកទីផ្សារជាពិសេសការតភ្ជាប់អាស៊ាន និងការជួយគ្នាទៅវិញទៅមក។

៩. **អាស៊ានជាច្រកនិងជាស្ពានការទូតដ៏ធំ**របស់កម្ពុជា ឆ្ពោះទៅកាន់តំបន់នានា និងផ្សារភ្ជាប់ទំនាក់ទំនងជាមួយដៃគូខាងក្រៅតាមរយៈដៃគូសន្ទនារបស់អាស៊ាន ដៃគូខាងក្រៅផ្សេងៗទៀត រួមទាំងអង្គការតំបន់ និងអង្គការអន្តរជាតិនានា។

**១០-** ចាប់តាំងពីបានក្លាយជាសមាជិកអាស៊ាន នៅថ្ងៃទី៣០ ខែមេសា ១៩៩៩មក កម្ពុជាបានធ្វើការយ៉ាងជិតស្និទ្ធជាមួយសមាជិកដទៃទៀត ក្នុងការកសាងសហគមន៍អាស៊ានមួយ ដៃល"**ផ្តោតលើប្រជាជន និងយកប្រជាជនជាស្នូល**" ក្នុងស្មារតីនៃ**ភាពម្ចាស់ការ និងការទទួលខុសត្រូវរួម** ។

បន្តទៅនេះ គឺជាប្រយោជន៍ទាំងឡាយដែលកម្ពុជាទទួលបានពីសមាជិកភាពរបស់អាស៊ាន ៖

## វិស័យនយោបាយ-សន្តិសុខ

**១១-** អាស៊ានគឺជាច្រកទ្វារ ជាស្ពាន ជាវេទិកាការទូតដ៏សំខាន់សម្រាប់កម្ពុជា ដែលតាមរយៈនេះ យើងអាចពង្រឹង និងពង្រីកទំនាក់ទំនងការទូត និងកិច្ចសហប្រតិបត្តិការអន្តរជាតិ របស់ខ្លួនលើឆាកតំបន់ និងអន្តរជាតិ។ ដោយមើលឃើញជោគជ័យ នៃសមាហរណកម្មតំបន់មួយនេះ និងការកើនឡើងនៃតួនាទី នយោបាយ សន្តិសុខ និងសេដ្ឋកិច្ចរបស់ ASEAN ប្រទេសជាច្រើនបានស្នើសុំក្លាយជាដៃគូ សន្ទនាជាមួយយើង។ ប្រទេស ៣៧ បានចូលរួមក្នុង TAC ក្នុងនោះ មានប្រទេស ១០ ជាដៃគូសន្ទនា (Australia, China, Canada, EU, Japan, India, ROK, NZ, Russia and USA) ហើយ ២៧ ទៀត ជាដៃគូតាម វិស័យ ឬក៏មិនទាន់ជាដៃគូ។ មានប្រទេសចំនួន ៩៦ បានដាក់ឯកអគ្គរដ្ឋ/រាជទូត របស់ខ្លួនប្រចាំនៅអគ្គលេខាធិកដ្ឋានអាស៊ាន។

១២- អាស៊ាន បានផ្ដល់ជាខែលសន្តិសុខជាទីទុកចិត្តមួយ ដល់ប្រទេសសមាជិក ក្នុងការពារឯករាជ្យភាព និងអធិបតេយ្យរបស់ខ្លួន។ ការគោរពគ្នា ការពិគ្រោះយោបល់ ការយោគយល់គ្នាទៅវិញទៅមក និងអត្ថប្រយោជន៍រួម បានក្លាយជាបទដ្ឋាននិងចំណុចខ្លាំងរបស់អាស៊ាន ក្នុងការធ្វើឱ្យយន្តការសំរាប់កិច្ចសន្ទនា និងការកសាងទំនុកចិត្តក្នុងអាស៊ាន។

## វិស័យសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន

១៣- កម្ពុជាទទួលបាននូវផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចយ៉ាងច្រើន ពីការចូលជាសមាជិកនៃក្រុមគ្រួសារអាស៊ាន។ ប្រទេសសមាជិកអាស៊ាន នាពេលបច្ចុប្បន្ន គឺជាទីផ្សារនាំចេញធំជាងគេទីបីរបស់កម្ពុជា បន្ទាប់ពីសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។ ទំហំពាណិជ្ជកម្មរបស់កម្ពុជាជាមួយប្រទេសសមាជិកអាស៊ានដទៃទៀត បានកើនឡើងពី៤ភាគរយនៅឆ្នាំ១៩៩៩ ទៅដល់ជាង២០ភាគរយនៅឆ្នាំ២០១៨។ អាស៊ានក៏ជាវិនិយោគិនមួយក្នុងចំណោមវិនិយោគិនធំជាងគេនៅកម្ពុជា។ នៅឆ្នាំ២០១៦ វិនិយោគទុនពីអាស៊ានមានប្រមាណជាង១៧ភាគរយ នៃវិនិយោគទុនដោយផ្ទាល់ពីបរទេសនៅកម្ពុជា។ ពាក់ព័ន្ធនឹងភ្ញៀវទេសចរណ៍បរទេសមកកម្ពុជា អាស៊ានស្ថិតក្នុងលំដាប់ខ្ពស់ទីពីរ ។

១៤- កិច្ចព្រមព្រៀង និងគំនិតផ្ដួចផ្ដើមនានាក្នុងសមាហរណកម្មសេដ្ឋកិច្ចអាស៊ានបានជួយសម្រួលដល់ដំណើរការសេដ្ឋកិច្ច ការវិនិយោគ និងការធ្វើពាណិជ្ជកម្មក្នុងតំបន់ និងក្នុងបណ្ដាប្រទេសអាស៊ាន ជាពិសេសក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទីផ្សារសេរី និងកិច្ចព្រមព្រៀងជាច្រើនទៀតជាមួយដៃគូអាស៊ាន។ បន្ថែមពីលើនេះ ការធ្វើសេរីភាវូបនីយកម្ម និងសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន បានជួយសម្រួលដល់ការធ្វើចរាចរទំនិញឆ្លង

កាត់ព្រំដែន លំហូរនៃទំនិញ សេវាកម្ម មូលធន និងពលករជំនាញ នៅក្នុងប្រទេសសមាជិកអាស៊ាន និងក្នុងតំបន់។

**១៥-** ជាក់ស្តែងក្នុងរយៈពេល២០ឆ្នាំកន្លងមកនេះ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់គួរឲ្យកត់សម្គាល់ជាមធ្យម ៧.៥% ហើយបានប្រែក្លាយខ្លួនពីប្រទេសដែលមានចំណូលកម្រិតទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ២០១៥។ កំណើនដ៏រឹងមាំ និងប្រកបដោយបរិយាប័ន្ននេះ បានរួមចំណែកយ៉ាងច្រើនក្នុងការលើកកម្ពស់ជីវភាពរស់នៅ កាត់បន្ថយភាពក្រីក្រ។ ជាក់ស្តែងផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗ បានកើនឡើងពី១.០៤២ ដុល្លាអាមេរិកនៅឆ្នាំ ២០១៣ ដល់ ១.៥៦៣ ដុល្លាក្នុងឆ្នាំ២០១៨ ខណៈអត្រានៃភាពក្រីក្របានធ្លាក់ចុះពីជាង ៥៣,៥% នៅឆ្នាំ២០០៤ មកនៅត្រឹមប្រមាណ៩% នៅឆ្នាំ ២០១៨ ។

**១៦-** កិច្ចសហប្រតិបត្តិការខាងផ្នែកតភ្ជាប់ទន់និងរឹងក្នុងតំបន់ មានសារៈសំខាន់ និងបានផ្តល់ផលប្រយោជន៍ជាច្រើន ដល់ប្រទេសសមាជិកអាស៊ាន និងកម្ពុជា ជាពិសេសក្នុងសកម្មភាពពាណិជ្ជកម្ម។ ការតភ្ជាប់នេះគឺប្រៀបបានទៅនឹងសរសៃឈាមនៃការកសាងសហគមន៍អាស៊ាន ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការតភ្ជាប់ស្ថាប័ន និងការតភ្ជាប់ទំនាក់ទំនងរវាងប្រជាជន និងប្រជាជន។ គម្រោងតភ្ជាប់រូបវន្តគ្រប់ដណ្តប់ទៅលើគំនិតផ្តួចផ្តើមជាច្រើន បានជួយសំរួលដល់លំហូទំនិញ សេវាកម្ម និងប្រជាជន នៅក្នុងតំបន់ ដែលរួមមាន បណ្តាញផ្លូវ អាស៊ានហាយវ៉េ កំពង់ផែសមុទ្រ និងបណ្តាញបែងចែកថាមពលអាស៊ាន។ គម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗទាំងនេះ នឹងនាំមកនូវផលប្រយោជន៍ជាច្រើន ដូចជាភាពប្រកួតប្រជែងនៃបណ្តាញផលិតកម្ម

តំបន់ពាណិជ្ជ កម្ម  សេវាកម្ម លំហូរវិនិយោគល្អប្រសើរជាងមុន និងការកាត់បន្ថយគម្លាតអភិវឌ្ឍន៍។

## វិស័យសង្គម-វប្បធម៌

**១៧-** កម្ពុជាទទួលបាននូវការអភិវឌ្ឍធនធានមនុស្ស និងការកសាងសមត្ថភាព តាមរយៈកិច្ចសហប្រតិបត្តិការវិស័យអប់រំ ការផ្លាស់ប្តូរទស្សនកិច្ចសិក្សា ការស្រាវជ្រាវ គម្រោងអភិវឌ្ឍន៍ជនបទ និងសុខមាលភាពសង្គម។ ក្រៅពីនេះ ក្រោមគម្រោងនៃគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន (IAI) កម្ពុជាទទួលបានការកសាងសមត្ថភាព និងការបណ្តុះបណ្តាលធនធានមនុស្ស នូវមុខជំនាញផ្សេងៗដល់មន្ត្រីតាមក្រសួង/ស្ថាប័ន និងផ្នែកឯកជនជាច្រើន (ដូចជាភាសាអង់គ្លេស ជំនាញក្នុងការសរសេរគម្រោង ច្បាប់ ធុរកិច្ច កសិកម្ម ព័ត៌មានវិទ្យា ការយល់ដឹងអំពីសហគ្រាសធុនតូច និងមធ្យម ជាដើម)។

**១៨-** ក្នុងវិស័យការងារ កិច្ចព្រមព្រៀងទទួលស្គាល់ទៅវិញទៅមកនៅក្នុងសហគមន៍អាស៊ានបានបើកឲ្យមានចរាចរដោយសេរីនៃអ្នកមានវិជ្ជាជីវៈជំនាញដូចជា វិស្វករ គិលានុបដ្ឋាក ស្ថាបត្យករ នគរូបនីយករ វេជ្ជបណ្ឌិតនិងទន្តពេទ្យ គណនេយ្យករ និងអ្នកមានវិជ្ជាជីវៈទេសចរណ៍។

## ទំនាក់ទំនងខាងក្រៅរបស់អាស៊ាន

**១៩-** ជាច្រើនឆ្នាំកន្លងទៅនេះ អាស៊ានបានពង្រឹង និងពង្រីក កិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយនឹងប្រទេស និងអង្គការក្រៅតំបន់នានាដែលជាទិសដៅសំខាន់របស់កម្ពុជាផងដែរ។ អាស៊ានមិនបានបង្កការគំរាមកំហែងដល់ប្រទេសណាមួយ ហើយថែមទាំងមិនបានចាប់បង្ខំភាគីដទៃ ឲ្យទទួលយកទស្សនទានរបស់ខ្លួនឡើយ។ មជ្ឈភាពអាស៊ាន ស្ថិតនៅជា

គោលការណ៍ស្នូលរបស់អាស៊ានក្នុងការសហការ និងទំនាក់ទំនងជាមួយដៃគូខាងក្រៅ។

**២០-** ក្នុងបរិបទនៃការកើនឡើងនូវជម្លោះភូមិសាស្ត្រនយោបាយ និងភាពមិនប្រាកដប្រជាក្នុងតំបន់ ដោយសារការប្រកួតប្រជែងរវាងមហាអំណាច ការស្ថិតនៅរួបរួមគ្នារបស់កម្ពុជានិងប្រទេសសមាជិកអាស៊ានដទៃទៀត កាន់តែមានសារៈសំខាន់ក្នុងការឆ្លើយតបរួមគ្នាទៅនឹង ហានិភ័យ និងបញ្ហាប្រឈមចំពោះមុខ។

**២១-** ***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្ស និស្សិត ទាំងអស់ជាទីរាប់អាន***

**២២-** ក្នុងពេល**កម្ពុជា**ធ្វើជា**ប្រធានអាស៊ានជាលើកដំបូង** នៅឆ្នាំ**២០០២** កម្ពុជាបានរៀបចំកិច្ចប្រជុំកំពូលពាក់ព័ន្ធជាច្រើន ជាពិសេសបានខិតខំពង្រឹងកិច្ចសហប្រតិបត្តិការរវាងអាស៊ាន និងឥណ្ឌា និងសម្របសម្រួលអោយមាន**កិច្ចប្រជុំកំពូលអាស៊ានឥណ្ឌាលើកទីមួយ**-។ **សេចក្តីថ្លែងការណ៍ ស្តីពីការប្រតិបត្តិរបស់ភាគីនៅក្នុងសមុទ្រចិនខាងត្បូង** )DOC (ត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីការបរទេសអាស៊ាន-ចិន កាលពីថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ ២០០២ នៅទីក្រុងភ្នំពេញ ។

**២៣-** នៅឆ្នាំ**២០១២** តាមរយៈការផ្តួចផ្តើមគំនិតរបស់កម្ពុជា **មជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន**) ARMAC) ត្រូវបានសម្រេចបង្កើតដើម្បីអនុវត្តគោលដៅសន្តិសុខ ក្នុងតំបន់ និងធ្វើឲ្យអាស៊ានជាតំបន់សន្តិភាព សន្តិសុខ អស់ហានិភ័យដោយគ្រាប់មីននិងសំណល់ជាតិផ្ទុះ ក៏ដូចជាដើម្បីពង្រឹងតួនាទីកម្ពុជាតាមរយៈអាស៊ាន ក្នុងកិច្ចសហប្រតិបត្តិការលើ

សកម្មភាពមនុស្សធម៌ជាមួយប្រទេស និង ស្ថាប័នជំនាញក្នុងតំបន់ និងក្រៅតំបន់។

**២៤-** ក្នុងដំណើរការកសាងសហគមន៍អាស៊ាន ក្នុងនាមជាសមាជិកសកម្មមួយ កម្ពុជាបាន និងកំពុងចូលរួម៖

## ក- ក្នុងដំណើរការកសាងសហគមន៍អាស៊ាន៖

- អនុវត្តនូវកាតព្វកិច្ចនានាដែលមានចែងនៅក្នុងធម្មនុញ្ញអាស៊ាន កិច្ចព្រមព្រៀង និង លិខិតុបករណ៍ទាំងឡាយរបស់អាស៊ាន ព្រមទាំងសេចក្តីសម្រេចផ្សេងៗទៀត ។
- អនុវត្តវិធាននានារបស់អាស៊ាន សម្រាប់សមាហរណកម្មសេដ្ឋកិច្ចកាន់តែស៊ីជម្រៅ តាមរយៈការសម្របសម្រួល ការកែសម្រួលវិធានច្បាប់ឲ្យកាន់តែមានភាពងាយស្រួល និងការធ្វើសុខដុមនីយកម្មរចនាសម្ព័ន្ធស្ថាប័ននិងបទប្បញ្ញត្តិនានា ព្រមទាំងការសម្របសម្រួលចរាចរទំនិញឆ្លងកាត់ព្រំដែន ការកាត់បន្ថយ ឬលុបបំបាត់របាំងមិនមែនពន្ធគយ។
- ចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តផែនការមេស្តីពីការតភ្ជាប់អាស៊ាន ដើម្បីភ្ជាប់តំបន់អាស៊ានឲ្យកាន់តែជិតស្និទ្ធ និងធ្វើសមាហរណកម្មកាន់តែស៊ីជម្រៅថែមទៀត។

## ខ- ក្នុងទំនាក់ទំនងអាស៊ានជាមួយដៃគូខាងក្រៅ៖

**២៥-** កម្ពុជាបាន និងកំពុងដើតួយ៉ាងសកម្មក្នុងការលើកកម្ពស់ទំនាក់ទំនងអាស៊ានជាមួយបណ្តាដៃគូសន្ទនា អាស៊ាន និងអង្គការក្នុងតំបន់ និងក្រៅតំបន់នានា តាមរយៈការដើតួនាទីជាប្រទេសសម្របសម្រួលទំនាក់ទំនងអាស៊ានជាមួយបណ្តាប្រទេសដៃគូមួយចំនួនដូចជា **សាធារណរដ្ឋប្រជាមានិត**

**ចិន សហភាពអឺរ៉ុប ឥណ្ឌា ជប៉ុន សាធារណរដ្ឋកូរ៉េ** និងបច្ចុប្បន្នជាមួយ វេលហ្សេឡង់ (ឆ្នាំ២០១៨-២០២១)ដោយយើងបានធ្វើជាសហប្រធាន ដឹកនាំកិច្ចប្រជុំគ្រប់កម្រិតពីថ្នាក់ក្រុមការងារ ឧត្តមមន្ត្រី រដ្ឋមន្ត្រីការបរទេស និងប្រមុខរដ្ឋ រដ្ឋាភិបាល។/

**២៦-** គួររំលឹកផងដែរថា ឆ្នាំ២០១២ ក្នុងឋានៈជាប្រធានអាស៊ាន កម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំជាច្រើន។ ក្នុងនោះ**សម្តេចអគ្គមហាសេនាបតី ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំកិច្ចប្រជុំកំពូលអាស៊ានពាក់ព័ន្ធ ដោយមានការចូលរួមពីថ្នាក់ដឹកនាំកំពូលនៃបណ្តាប្រទេសធំៗ លើពិភពលោក ដូចជា អូស្ត្រាលី ចិន ជប៉ុន សាធារណរដ្ឋកូរ៉េ ឥណ្ឌា ណូវែលហ្សេឡង់ រុស្ស៊ី និងសហរដ្ឋអាមេរិក (Obama)។ នៅក្នុងទំនាក់ដៃគូខាងក្រៅរបស់អាស៊ាន កម្ពុជាបាន ចូលរួមចំណែកយ៉ាងសកម្មមានជាអាទិ៍ រក្សាតួនាទីស្នូលរបស់អាស៊ានក្នុងការដោះស្រាយបញ្ហាប្រឈមនានា ដែលធ្វើឲ្យប៉ះពាល់ដល់សន្តិភាព សន្តិសុខ និងស្ថិរភាពក្នុងតំបន់។

- ចូលរួមយ៉ាងសកម្មក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ**អាស៊ីបូព៌ា** និងគាំទ្រដល់ដំណើរការកសាងសហគមន៍អាស៊ីបូព៌ាក្នុងគោលដៅយូរទៅខាងមុខ។
- បានចូលរួមជាមួយសមាជិកអាស៊ាន ក្នុងការរៀបចំឯកសារទស្សនទានស្តីពី **ទស្សនវិស័យអាស៊ានស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិក** (ASEAN Indo-Pacific Outlook( ដែលឈរលើគោលការណ៍មជ្ឈភាពអាស៊ាន ភាពទូលំទូលាយ តម្លាភាព បរិយាប័ន្ន បំពេញបន្ថែមឲ្យគ្នា និងការទុកចិត្តគ្នា។

*ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី*

*ក្មួយៗ ទាំងអស់ជាទីរាប់អាន*

**២៧-** ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កម្ពុជាបានក្លាយជាសមាជិកស្មើភាព និងស្មើសិទ្ធិនៅក្នុងអាស៊ាន ក៏ដូចជាស្មើភាព និងស្មើសិទ្ធិជាមួយនឹងបណ្តាប្រទេសដ៏ទៃទៀតនៅគ្រប់វេទិកាតំបន់ និងពិភពលោក។ នេះជាមោទនភាព និងសេចក្តីថ្លៃថ្នូរដ៏ធំធេងរបស់ជាតិយើង។

**២៨-** ព្រមជាមួយគ្នានេះ កម្ពុជាក៏នឹងកំពុងនឹងជួបប្រទះនូវ**បញ្ហាប្រឈមមួយចំនួន**បើប្រៀបធៀបនឹងប្រទេសសមាជិកអាស៊ានដទៃ ដូចជា៖ ធនធានមនុស្ស និងការពង្រឹងសមត្ថភាពស្ថាប័ននៅមានកម្រិត កង្វះពលកម្មជំនាញ កង្វះហេដ្ឋារចនាសម្ព័ន្ធ និងប្រភពធនធាន ការអនុវត្តកិច្ចព្រមព្រៀងអាស៊ានផ្សេងៗនៅថ្នាក់ជាតិមិនទាន់មានភាពស៊ីជម្រៅ និងបានទូលំទូលាយ។ ប្រភពធនធាន និងមូលនិធិជាតិសម្រាប់ការអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យមនៅមានកម្រិត មូលដ្ឋានគ្រឹះសេដ្ឋកិច្ចនៅមានកម្លាំងតូច ដែលពុំទាន់អនុញ្ញាតឲ្យមានកម្លាំងប្រកួតប្រជែងរឹងមាំ គម្លាតអភិវឌ្ឍន៍រវាង និងក្នុងចំណោមប្រទេសសមាជិកអាស៊ាន កង្វះបច្ចេកវិទ្យាជាបញ្ហាគន្លឹះ ដែលកម្ពុជាបាននិងកំពុងប្រឈម។

*ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី*

*ក្មួយៗ ទាំងអស់ជាទីរាប់អាន*

**២៩-** ជាការពិត អាស៊ាន មិនមែនជាអង្គការល្អឥតខ្ចោះទេ ។ អាស៊ាន នៅមានចំនុចខ្សោយនិងបញ្ហាប្រឈមខាងស្ថាប័នជាច្រើនដែលត្រូវដោះស្រាយ ។ ក៏ប៉ុន្តែ ប្រសិនបើគ្មានអាស៊ាន តំបន់អាស៊ីអាគ្នេយ៍ទាំងមូល ក៏មិនអាចសម្រេចបាននូវសន្តិភាព និងវិបុលភាពដូចសព្វថ្ងៃនោះដែរ។

**៣០-** ឆ្នាំ ២០១៩ និងបណ្តាឆ្នាំតទៅមុខ ស្ថានការណ៍ពិភពលោកនឹងបន្តប្រែប្រួលយ៉ាងជ្រាលជ្រៅ ស្មុគស្មាញ ឆាប់រហ័ស និងពិបាកប៉ាន់ស្មានបាន ។

**៣១-** ដំណើរប្រែប្រួលទៅកាន់ប្រព័ន្ធពហុប៉ូលនៅបន្តទៅមុខ។ ការងើបឡើងកាន់តែជាក់ច្បាស់របស់តួអង្គថ្មីៗនៅលើឆាកអន្តរជាតិ នឹងទាញការទទួលខុសត្រូវក្នុងការចាត់ចែងកិច្ចការពិភពលោកទៅរកប៉ូលថ្មី បង្កើតជាការប្រកួតប្រជែងជាយុទ្ធសាស្ត្រ ដើម្បីអំណាច ឥទ្ធិពល និងផលប្រយោជន៍។

**៣២-** ការងាកចេញរបស់មហាអំណាចទី ១ ពីប្រព័ន្ធពហុភាគីនិយម ទៅកាន់ឯកតោភាគីនិយម និងគាំពារនិយម កំពុងគំរាមដល់ប្រព័ន្ធសណ្តាប់ធ្នាប់ពិភពលោកបច្ចុប្បន្ន ដែលជាវិធានសម្រាប់ចាត់ចែងទំនាក់ទំនងអន្តរជាតិ អស់កាលជាង៧០ឆ្នាំមកហើយ។

**៣៣-** ភ្នក់ជម្លោះតាមតំបន់នានានៅមជ្ឈិមបូព៌ា អឺរ៉ុបខាងកើត អាហ្វ្រិក អាមេរិកឡាទីន និងនៅអាស៊ី ( PK / nucleaire – Rakhine State ) បញ្ហាប្រឈមធ្ងន់ធ្ងរ តួយ៉ាង អំពើភេរវកម្ម វិបត្តិជនភៀសខ្លួន ឧក្រិដ្ឋកម្មបច្ចេកវិទ្យាព័ត៌មានវិទ្យា ឧក្រិដ្ឋកម្មឆ្លងដែន ការជួញដូរមនុស្ស/គ្រឿងញៀន ការប្រែប្រួលធាតុអាកាស និងបញ្ហាបរិស្ថាន ជំងឺឆ្លង និងគ្រោះធម្មជាតិ។ល។ នឹងនៅតែបន្តគំរាមកំហែងដល់សន្តិសុខពិភពលោក និងត្រូវការការរួមកម្លាំងទាំងអស់គ្នាដើម្បីឆ្លើយតបដោះស្រាយ។

**៣៤-** តំបន់អាស៊ី-ប៉ាស៊ីហ្វិក នឹងនៅតែជាចំណុចកណ្តាលនៃការប្រកួតប្រជែងរបស់មហាអំណាចធំៗ។ ការងើបឡើងរបស់បណ្តាប្រទេសនៅអាស៊ី នាំមុខដោយ ចិន ជប៉ុន ឥណ្ឌា កូរ៉េខាងត្បូង និងអាស៊ាន កំពុងធ្វើឲ្យជញ្ជីងអំណាចផ្អៀងពីភាគខាងលិចមកភាគខាងកើត ធ្វើឲ្យតំបន់នេះក្លាយជាចំនុចកណ្តាលនៃការប្រកួតប្រជែងរបស់មហាអំណាចធំៗតទៅទៀត។

**៣៥-** ប្រទេសសមាជិកអាស៊ាននានា សុទ្ធតែទទួលរងឥទ្ធិពល និងសំពាធដោយឡែកពីគ្នាពីការប្រណាំងប្រជែងខាងភូមិសាស្ត្រនយោបាយ របស់ប្រទេសមហាអំណាចក្នុងកម្រិត និងក្រោមរូបភាពខុសៗគ្នា។

**៣៦-** ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ នៅតែបន្តដាក់សម្ពាធទៅលើការរក្សាមជ្ឈភាព និងឯកភាពរបស់សហគមន៍អាស៊ាន។ យ៉ាងណាក្តី ប្រទេសនានានៅក្នុងតំបន់ និងពិភពលោកនៅតែបន្តផ្តល់ទំនុកចិត្តទៅលើនិម្មាបនកម្មដែលអាស៊ានបានកសាងឡើង។ ជាក់ស្តែង យន្តការដូចជា តំបន់ពាណិជ្ជកម្មសេរីអាស៊ាន វេទិកាតំបន់អាស៊ាន អាស៊ានបូកមួយ អាស៊ានបូកបី កិច្ចប្រជុំកំពូលអាស៊ីបូព៌ា កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការពារជាតិអាស៊ានបូកជាដើម និងនៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាស្ថិរភាព សន្តិសុខ និងលើកស្ទួយវិបុលភាពក្នុងតំបន់។

**៣៧-** ជោគជ័យនៃសមាហរណកម្មតំបន់មួយនេះ បាននឹងបន្តទាក់ទាញចំណាប់អារម្មណ៍ដ៏ខ្លាំងពីសំណាក់ប្រទេសនានានៅលើលោកដែលប្រទេសនីមួយៗ សុទ្ធតែសុំក្លាយជាដៃគូរបស់អាស៊ាន។

**៣៨-** ឆ្ពោះទៅអនាគតខាងមុខ កម្ពុជានឹងបន្តដើរតួនាទីបុរេសកម្ម និងប្រកបដោយការទទួលខុសត្រូវ ដើម្បីធានាថា អាស៊ាននៅតែជាចំនុចស្នូលនៃនិម្មាបនកម្មតំបន់ តាមរយៈការប្រកាន់ខ្ជាប់នូវស្មារតីអាស៊ាន និងអាស៊ានមួយ

ដែលឈរលើវិធានច្បាប់។ លក្ខណៈពិសេសនៃយុទ្ធសាស្ត្រសមាហរណកម្ម តំបន់របស់កម្ពុជា គឺសុខដុមនីយ៍កម្មរវាងអត្ថប្រយោជន៍ជាតិ និងផលប្រយោជន៍រួមរបស់អាស៊ាន ដោយព្យាយាមរក្សាតុល្យភាពសមស្របជាមួយដៃគូខាងក្រៅ និងដោយខិតខំពង្រីកបន្ថែមការតភ្ជាប់ដើម្បីសម្រេចឲ្យបាននូវសហគមន៍អាស៊ានដែលយកប្រជាជនជាស្នូល និងបម្រើផលប្រយោជន៍ប្រជាជន។

៣៩- ខ្ញុំសង្ឃឹមថា បទឧទ្ទេសនាមរបស់ខ្ញុំបានផ្តល់ការយល់ដឹងបន្ថែមដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សនិស្សិត ស្តីពីប្រវត្តិ សារៈសំខាន់ និងការរួមវិភាគទានរបស់កម្ពុជាក្នុងសមាគមន៍អាស៊ាន។

៤០- ជាបញ្ចប់ ខ្ញុំសង្ឃឹមថា ឯកឧត្តម លោកជំទាវ លោកលោកស្រី ក្មួយៗសិស្ស-និស្សិត ទាំងអស់ទទួលបានការយល់ដឹងអំពីសហគមន៍អាស៊ានតួនាទីរបស់កម្ពុជានៅក្នុងអាស៊ាន ជាពិសេសអត្ថប្រយោជន៍ដែលកម្ពុជាទទួលបាន។ ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមសហការរៀបចំកម្មវិធីនេះ។ សូមឯកឧត្តម លោកជំទាវ លោក-លោកស្រី ក្មួយៗសិស្ស-និស្សិតទាំងអស់ ទទួលបាននូវពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។**

**សូមអរគុណ!**